នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជតក |
| ដាក់ទៅ | : | អង្គជំនុំជម្រះតុលាការកំពូល |
| ថ្ងៃដាក់ | : | ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៩ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 22-Jul-2019, 15:37
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះតុលាការកំពូល: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

# ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ ខៀវ សំផន សុំបន្ថែមពេលវេលា និង ចំនួនទំព័រកំណត់ សម្រាប់សារណាបណ្ដឹងសាទុក្ខ

---

**អ្នកដាក់ឯកសារ:**

**សហព្រះរាជអាជ្ញា:**
លោកស្រី ជា លាង
លោកស្រី Brenda J. HOLLIS
(បម្រុង)

**អ្នកទទួលឯកសារ:**

**អង្គជំនុំជម្រះតុលាការកំពូល:**
ចៅក្រម គង់ ស្រីម, ប្រធាន
ចៅក្រម C. N. JAYASINGHE
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម Florence Ndepele MUMBA
ចៅក្រម ម៉ុង មុនីចរិយា
ចៅក្រម Phillip RAPOZA
ចៅក្រម យ៉ា ណារិន

**ចម្លងជូន:**

**សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី:**
លោក ពេជ អង្គ

**ជនជាប់ចោទ:**
នួន ជា
ខៀវ សំផន

**មេធាវីការពារក្ដីជនជាប់ចោទ:**
លោក សុន អរុណ
លោក លីវ សុវណ្ណា
លោកស្រី Doreen CHEN
លោក គង់ សំអុន
លោកស្រី Anta GUISSÉ

## I. សេចក្ដីផ្ដើម

1. សហព្រះរាជអាជ្ញាសូមជំទាស់ទៅនឹងសំណើសុំពន្យារពេលវេលា និងបន្ថែមចំនួនទំព័រកំណត់ច្រើនហួសហេតុដែលបានធ្វើឡើងដោយ ខៀវ សំផន សម្រាប់សារណាបណ្ដឹងសាទុក្ខរបស់គាត់[1]។ សំណើសុំពន្យារពេលវេលា និងបន្ថែមចំនួនទំព័រកំណត់នេះមិនធ្លាប់បានធ្វើកន្លងមកទេ និងក៏មិនធ្លាប់ត្រូវបានអនុញ្ញាត ក្នុងកាលៈទេសៈផ្សេងៗ ហើយក៏មិនស្ថិតក្នុងផលប្រយោជន៍នៃយុត្តិធម៌នោះដែរ។ ក្នុងពេលជាមួយគ្នា សហព្រះរាជអាជ្ញាទទួលស្គាល់ថា ការពន្យារពេលវេលា និងបន្ថែមចំនួនទំព័រ គឺពិតជាមានយុត្តិកម្មទៅនឹងសារណាបណ្ដឹងសាទុក្ខនៅក្នុងករណីនេះ ប៉ុន្តែការពន្យារពេល និងបន្ថែមទំព័រដូច្នេះ ត្រូវតែសមហេតុផល និងអនុវត្តដោយស្មើភាពគ្នាចំពោះភាគីទាំងអស់។

## II. ប្រវត្តិនីតិវិធី

2. នៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩ អង្គជំនុំជម្រះសាលាដំបូង បានផ្ដល់សាលក្រមដែលមានសំអាងហេតុពេញលេញរបស់ខ្លួន[2]។ នៅថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៩ ខៀវ សំផន បានស្នើសុំរយៈពេលសរុបចំនួន ២៤០ថ្ងៃ និង១០០០ទំព័រ ជាភាសាបារាំង ដើម្បីដាក់សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខរបស់ខ្លួន[3]។ នៅថ្ងៃដដែល នួន ជា ក៏បានស្នើរយៈពេលសរុប ១៨០ថ្ងៃ និង១០០ទំព័រ ជាភាសាអង់គ្លេស ដើម្បីដាក់សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខរបស់គាត់[4]។

3. នៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៩ អង្គជំនុំជម្រះតុលាការកំពូល បានផ្ដល់ការអនុញ្ញាតដល់គូភាគីនូវការពន្យារពេល២ខែ និងបន្ថែមទំព័រពី៣០ ដល់ ៦០ទំព័រ សម្រាប់សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខ[5]។ នៅថ្ងៃទី៣ ខែឧសភា ឆ្នាំ២០១៩ ខៀវ សំផន បានស្វែងរកឲ្យមានការពិនិត្យឡើងវិញ

---

[1] ឯកសារ **F45** សំណើរបស់មេធាវីការពារក្ដីលោក ខៀវ សំផន សុំបន្ថែមពេលវេលា និងចំនួនទំព័រនៃសារណាបណ្ដឹងសាទុក្ខ (“សំណើរបស់ ខៀវ សំផន”)។

[2] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២, ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៨។

[3] ឯកសារ **F39/1.1** សំណើរបស់លោក ខៀវ សំផន សុំពន្យារពេល និងបន្ថែមចំនួនទំព័រនៃសេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខ, ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៩, កថាខណ្ឌ៤២ (“សំណើសុំទាក់ទងនឹងសេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន”)។

[4] ឯកសារ **F40/1.1** សំណើបន្ទាន់លើទីមួយរបស់ នួន ជា សុំចំនួនទំព័រ និងពេលវេលាបន្ថែម សម្រាប់ការដាក់ជូនសេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខជំទាស់ទៅនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង០០២/០២, ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៩, កថាខណ្ឌ ១។

[5] ឯកសារ **F43** សេចក្ដីសម្រេចលើសំណើរបស់ នួន ជា និង ខៀវ សំផន សុំបន្ថែមពេលវេលា និងចំនួនទំព័រ សម្រាប់ដាក់សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខ, ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៩។

លើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល[6] ដោយអះអាងថាគាត់មិនអាចធ្វើការកំណត់អត្តសញ្ញាណកំហុសឆ្គងនានាឲ្យបានពេញលេញនៅក្នុងសាលក្រមរបស់សាលាដំបូងបានឡើយ បើតាមរយៈពេលវេលា និងចំនួនទំព័របន្ថែមដែលបានផ្តល់ដោយអង្គជំនុំជម្រះតុលាការកំពូល[7]។ អង្គជំនុំជម្រះតុលាការកំពូលបានទាត់ចោលសំណើចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៩ របស់ ខៀវ សំផន នេះ ដោយកត់សំគាល់ថា វាមាន "ភាពច្រំដែលច្រើន" ជាមួយនឹងសំណើដើមរបស់គាត់ និងការឆ្លើយតបរបស់គាត់ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញា[8]។

4. នៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៩ ខៀវ សំផន បានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់គាត់ជាអ្វី[9] ដែលគេបានបញ្ជាក់ថាជា ទទ្បីរណ៍នៃបណ្តឹងសាទុក្ខមានចំនួន ១៨២៤ និងសេចក្តីសម្រេចដែលអាចប្តឹងសាទុក្ខមានចំនួន៣៥៥[10]។ ក្នុងថ្ងៃនោះ នួន ជា បានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់គាត់ដោយចោទថា មានទទ្បីករណ៍ ៣៥១ សម្រាប់បណ្តឹងសាទុក្ខ[11]។

5. នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៩ ខៀវ សំផន បានស្នើសុំពេលវេលារហូតដល់ ១០ខែកន្លះ និង ៩៥០ ទំព័រ សម្រាប់សារណាបណ្តឹងសាទុក្ខរបស់គាត់[12]។ ខៀវ សំផន បានស្នើសុំរយៈពេល៤០ថ្ងៃបន្ថែមទៀត ដើម្បីឆ្លើយតបទៅនឹងសារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ដែលនឹងចាប់គិតបន្ទាប់ពីការដាក់សារណាបណ្តឹងសាទុក្ខរបស់គាត់ ឬបើតាមរបៀបផ្សេងពីនេះ គាត់បានស្នើសុំឲ្យអង្គជំនុំជម្រះតុលាការកំពូល ធ្វើការកំណត់កាលបរិច្ឆេទសវនាការជាសាធារណៈលើបញ្ហានេះ[13]។

## III. ចម្លើយតប

---

[6] ឯកសារ **F44** សំណើរបស់លោក ខៀវ សំផន សុំឲ្យពិនិត្យឡើងវិញលើសេចក្តីសម្រេចស្តីពីការសុំបន្ថែមពេលវេលា និងបង្កើនចំនួនទំព័រ សម្រាប់ដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ, ចុះថ្ងៃទី៣ ខែឧសភា ឆ្នាំ២០១៩

[7] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ១០។

[8] ឯកសារ **F44/1** សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំឱ្យពិចារណាឡើងវិញនូវសេចក្តីសម្រេចអំពីការស្នើសុំបន្ថែមពេលវេលា និងចំនួនទំព័រលើសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ, ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៩។

[9] ឯកសារ **E465/4/1** សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់លោក ខៀវ សំផន (សំណុំរឿង ០០២/០២), ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៩។

[10] ឯកសារ **F45** សំណើរបស់ ខៀវ សំផន, កថាខណ្ឌ ៩។

[11] ឯកសារ **E465/3/1** សេចក្តីជូនដំណឹងរបស់ នួន ជា អំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០២, ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៩។

[12] ឯកសារ **F45** សំណើរបស់ ខៀវ សំផន, កថាខណ្ឌ ១៩។

[13] ឯកសារ **F45** សំណើរបស់ ខៀវ សំផន, កថាខណ្ឌ ៣៩។

*(i) ខៀវ សំផន ខកខានមិនបានផ្តល់យុត្តិកម្មចំពោះសំណើសុំពន្យារពេលវេលា និងបន្ថែមចំនួនទំព័រកំណត់ច្រើនហួសហេតុសម្រាប់បណ្តឹងសាទុក្ខរបស់គាត់ទេ*

6. សហព្រះរាជអាជ្ញាទទួលស្គាល់ថា ខៀវ សំផន គឺត្រឹមត្រូវដែលស្នើសុំពន្យារពេលវេលា និងបន្ថែមចំនួនទំព័រកំណត់សម្រាប់បណ្តឹងសាទុក្ខរបស់គាត់ក្នុងករណីនេះ។ ប៉ុន្តែ ទំហំ និងភាពស្មុគស្មាញនៃសាលក្រមសំណុំរឿង០០២/០២នេះ មិនមានយុត្តិកម្មទៅនឹងសំណើសុំពេលវេលាបន្ថែមដែលបានស្នើសុំដោយ ខៀវ សំផន នោះឡើយ។

7. ទោះបីតាមគណិតសាស្ត្រណាក៏ដោយ ក៏សំណើរបស់ ខៀវ សំផន មិនសមហេតុផលដែរ។ ផ្ទុយទៅនឹងការអះអាងរបស់ ខៀវ សំផន[14] ចំនួនទំព័រសរុប គឺវាមាលក្ខណៈសាមញ្ញពេក សម្រាប់ជាមធ្យោបាយមួយក្នុងការគណនាទៅលើពេលវេលា និងចំនួនទំព័រដែលត្រូវការ។ ការកំណត់ទៅលើកាលបរិច្ឆេទកំណត់ និងប្រវែងសារណាឲ្យបានសមរម្យ មិនគួរជាដំណើរការបែបគ្រឿងម៉ាស៊ីនណាមួយទេ ចំណែក ខៀវ សំផន វិញ គាត់បានខកខានក្នុងការបង្ហាញឲ្យឃើញពីរបៀប ដែលសាលក្រមមួយដែលមានប្រវែងវែងជាងបីដង ចាំបាច់ត្រូវមានបណ្តឹងសាទុក្ខដែលមានប្រវែងបីដងដូចគ្នាដែរនោះទេ។ តាមគណិតសាស្ត្រជាមូលដ្ឋាន គាត់ខកខានមិនបានពិចារណា ជាឧទាហរណ៍ទៅលើភាពជាន់គ្នានៃអង្គហេតុជាសារវន្តរវាងសំណុំរឿង០០២/០១ និងសំណុំរឿង ០០២/០២ ទេ។ ស្រដៀងគ្នានេះដែរ ការពឹងផ្អែករបស់ ខៀវ សំផន លើចំនួនដ៏ច្រើននៃកំណត់សំគាល់ជើងទំព័រនៅក្នុងសាលក្រមសំណុំរឿង០០២/០២ តាមរបៀបប្រៀបធៀប ដោយមិនបានគិតពីបញ្ហាឆ្លងគ្នាទៅនឹងផ្នែកផ្សេងទៀតនៃសាលក្រម[15]។

8. ខៀវ សំផន ក៏ខកខានមិនបានបង្ហាញឲ្យឃើញពីកម្រិតនៃធនធានបច្ចុប្បន្នរបស់គាត់ដែលនាំឲ្យមានការអនុញ្ញាតតាមសំណើសុំពន្យារពេល និងបន្ថែមចំនួនទំព័រ។ តាមសំណើសុំបន្ថែមពេលវេលា និងចំនួនទំព័រកំណត់របស់ខ្លួន ខៀវ សំផន បានលើកឡើងដដែលៗអំពីកង្វះធនធានផ្សេងៗ ក្នុងការប្រៀបធៀបទៅនឹងដំណាក់កាលសវនាការ[16]។ យ៉ាងណាមិញ បណ្តឹងសាទុក្ខមិនអាចសន្មតថានឹងដូចគ្នាទៅនឹងដំណាក់កាលសវនាការនោះទេ។ ដូចអង្គជំនុំជម្រះតុលាការកំពូលបានថ្លែងថា "អង្គជំនុំជម្រះសាលាដំបូង គឺជា "ស្ថាប័នស្នូលដែលមានភារកិច្ចក្នុងការសម្រេចអំពីអង្គហេតុ"" ហើយ

---

[14] ឯកសារ F45 សំណើរបស់ ខៀវ សំផន, កថាខណ្ឌ ១៦។

[15] ឯកសារ F45 សំណើរបស់ ខៀវ សំផន, កថាខណ្ឌ ១៦។

[16] ឯកសារ F45 សំណើរបស់ ខៀវ សំផន, កថាខណ្ឌ ១៦។ សូមមើលផងដែរ F39/1.1 អំពីការជូនដំណឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ២៨-៣៤។

ចំណែកតួនាទីរបស់អង្គជំនុំជម្រះតុលាការកំពូល គឺដើម្បីផ្ទៀងផ្ទាត់ថា បន្ទុកនៃការកំណត់ធាតុផ្សំនៃបទចោទឲ្យហួសពីវិមតិសង្ស័យនោះ ត្រូវបានបំពេញ ដោយមិនមានការពាក់ព័ន្ធនៅក្នុងការវាយតម្លៃលើភស្តុតាង*សាឡើងវិញ*[17]។

### *(ii) សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខមិនគ្រប់គ្រាន់ របស់ ខៀវ សំផន មិនមែនជាយុត្តិកម្មដើម្បីទទួលបានពេលវេលា និងចំនួនទំព័របន្ថែម សម្រាប់សារណាបណ្តឹងសាទុក្ខរបស់គាត់ឡើយ*

9. ខៀវ សំផន ខកខានក្នុងការបង្ហាញឲ្យឃើញថាតើជម្រើសរបស់គាត់ក្នុងការដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខមិនគ្រប់គ្រាន់ អាចមានយុត្តិកម្មដល់ការបន្ថែមពេលវេលា និងចំនួនទំព័រដ៏ច្រើនដែលគាត់កំពុងស្នើសុំនាពេលនេះដោយរបៀបណានោះទេ។ ខៀវ សំផន អះអាងថា គាត់មិនមានពេលគ្រប់គ្រាន់ដើម្បីបញ្ជាក់ពីការគាំទ្រខាងអង្គច្បាប់ និងអង្គហេតុ ដែលជាមូលដ្ឋាននៃការរកឃើញរបស់អង្គជំនុំជម្រះសាលាដំបូង និងនិយាយថា ពេលវេលា និងចំនួនទំព័រ ដែលបានស្នើសុំសម្រាប់សារណាបណ្តឹងសាទុក្ខរបស់គាត់នេះ មួយផ្នែក គឺជាការបំពេញការងារដែលគាត់មិនមានលទ្ធភាពបញ្ចប់សម្រាប់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់គាត់។[18] ការណ៍នេះមិនមែនជាមូលដ្ឋានត្រឹមត្រូវមួយសម្រាប់សំណើសុំរបស់គាត់នោះទេ។ នៅក្នុងរឿងក្តីព្រហ្មទណ្ឌ គូភាគីត្រូវបានផ្តល់នូវពេលវេលាមួយដែលមានកាលកំណត់ ដើម្បីបំពេញកាតព្វកិច្ចរបស់ខ្លួន។ បន្ទាប់មក គឺវាអាស្រ័យទៅលើភាគីនីមួយៗ ថាត្រូវរៀបចំធនធានរបស់ខ្លួននៅក្នុងរយៈពេលនោះ ដើម្បីឲ្យការងាររបស់ខ្លួនដោយរបៀបណា[19]។ ការអនុញ្ញាតឲ្យ ខៀវ សំផន ទទួលបានពេលវេលាបន្ថែម នៅក្នុងអំឡុងពេលនៃនីតិវិធីសារណាបណ្តឹងសាទុក្ខ ដើម្បីឲ្យបានសម្រេចការងារដែលគាត់ខកខានមិនបានសម្រេច នៅក្នុងអំឡុងពេលនៃដំណាក់កាលនៃការជូនដំណឹងអំពីបណ្តឹងសាទុក្ខ នឹងធ្វើឲ្យគោលបំណងនៃការរៀបចំកាលបរិច្ឆេទកំណត់បរាជ័យតាំងពីដំបូង។

---

[17] ឯកសារ **F36** សាលដីកាសំណុំរឿង០០២/០១, ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៦, កថាខណ្ឌ ២៩ ("សាលដីកាសំណុំរឿង ០០២/០១")។

[18] ឯកសារ **F45** សំណើរបស់ ខៀវ សំផន កថាខណ្ឌ ១៨។

[19] *សូមមើល ឧទាហរណ៍* ឯកសារ **F6/2** សេចក្តីសម្រេចលើសំណើរបស់សហមេធាវីការពារក្តីជនជាប់ចោទ កាំង ហ្គេកអ៊ាវ *ហៅ* ឌុច សុំពន្យារពេល កំណត់សម្រាប់ដាក់សារណាបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ របស់អង្គជំនុំជម្រះសាលា ដំបូង ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០ កថាខណ្ឌ ៩ "ពាក់ព័ន្ធនឹងទំហំធនធានដែលជនជាប់ចោទមាន អង្គជំនុំជម្រះតុលាការកំពូល ធ្វើការបញ្ជាក់ថា តាមការអនុវត្តសិទ្ធិជ្រើសរើសតំណាងរបស់ខ្លួន ជនជាប់ចោទត្រូវតែគិតអំពីភាពចាំបាច់ក្នុងការគោរពនូវ កាលបរិច្ឆេទដើម្បីកុំឲ្យអូសបន្លាយនីតិវិធីឥតសមហេតុផល"។

10. ជាងនេះទៀត វាមិនសមហេតុផលដែលថា ខៀវ សំផន នឹងត្រូវការបន្ថែមចំនួនទំព័រដ៏ច្រើនបែបនេះ ប្រសិនបើ តាមការពិត ផែនការរបស់គាត់ត្រូវធ្វើសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខដែលឲ្យកាន់តែច្បាស់ជាងនេះ[20]។ ថ្វីត្បិតតែការពិនិត្យឡើងវិញយ៉ាងប្រញាប់ប្រញាល់លើសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ ខៀវ សំផន បង្ហាញឲ្យឃើញពីទឡ្ហីករណ៍ជាច្រើនដែលស្រដៀងគ្នា ឬ ដូចគ្នាយ៉ាងខ្លាំងនៅក្នុងខ្លឹមសារក្តី[21] តែនោះគឺអ្វីដែលគេបានរំពឹងថា នឹងត្រូវបានជូនដំណឹងនៅពេលកំពុងធ្វើសេចក្តីព្រាង។ ដោយហេតុថា សារណាបណ្តឹងសាទុក្ខគួរបានបង្រួមបញ្ចូលនូវទឡ្ហីករណ៍ដែលជាន់គ្នាឲ្យមកតែមួយ នោះការធ្វើបែបនេះនាំឲ្យចំនួនទំព័រដែលត្រូវការ នឹងតិចជាងមុន។ ពេលវេលាបន្ថែម ជាទូទៅត្រូវបានអនុញ្ញាត គឺដើម្បីឲ្យប្រាកដថា ភាគីនានាអាចផ្តោតលើការត្រៀមរៀបចំបានច្រើនទៅលើការដាក់សារណា ដែលបើដូច្នេះ វានឹងនាំឲ្យមានការកាត់បន្ថយចំនួនទំព័រដែលត្រូវការ។ តាមការអនុវត្ត ពេលវេលាបន្ថែមដ៏សមរម្យ គួរតែអមដោយចំនួនទំព័របន្ថែមសមល្មម។

---

[20] *សូមមើល* ជាឧទាហរណ៍ *ដួអាជ្ញា ទល់នឹង* *Milorad Krnojelac*, IT-97-25-A, សេចក្តីសម្រេចសំណើរបស់រដ្ឋអាជ្ញាសុំការអនុញ្ញាតលើសចំនួនទំព័រកំណត់ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០០២ ទំព័រ២ "យល់ឃើញថា គុណភាព និងប្រសិទ្ធិភាពនៃសារណាបណ្តឹងសាទុក្ខមិនពឹងផ្អែកលើប្រវែងរបស់វានោះតែ តែលើភាពច្បាស់លាស់ និងភាពសមហេតុផលនៃអំណះអំណាងដែលលើកឡើង និងថា ហេតុដូច្នេះ សារណាដែលវែងហួសហេតុបានបម្រើឲ្យបុព្វហេតុនៃរដ្ឋបាលតុលាការប្រកបដោយប្រសិទ្ធិភាពនោះទេ"។

[21] ជាឧទាហរណ៍នៃទឡ្ហីករណ៍ជាន់គ្នានៅក្នុងសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ ខៀវ សំផន រួមមាន៖ ទឡ្ហីករណ៍ 18.206 និង 18.35 (ទាំងពីរនេះលើកឡើងអំពីការបោសសម្អាតដែលជាប់ទាក់ទងមិនអាចផ្តាច់ពីគ្នាបាន ទៅនឹង មន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្ស)។ ទឡ្ហីករណ៍ 16.206 និង 16.237 (ទាំងពីរនេះលើកឡើងអំពីគោលនយោបាយ កំណត់អត្តសញ្ញាណ ដាក់ឲ្យនៅដាច់ពីគេ និង កំទេច ពួក ខ្មាំងដ៏មានគ្រោះថ្នាក់បំផុត)។ ទឡ្ហីករណ៍ 16.231, 12.110, 16.354 និង 16.350 (ទាំងអស់នេះលើកឡើងអំពីការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយនៅស-២១)។ ទឡ្ហីករណ៍ 16.221, 12.108 និង 16.222 (ទាំងអស់នេះលើកឡើងអំពីឧក្រិដ្ឋកម្មនៃការធ្វើមនុស្សឃាត នៅស-២១)។ ទឡ្ហីករណ៍ 16.349 និង 18.255 (ទាំងពីរនេះលើកឡើងអំពីការធ្វើមនុស្សឃាតទៅលើ អតីតខ្មែរក្រហម នៅស-២១ និងក្រាំងតាចាន់)។ ទឡ្ហីករណ៍ 16.300, 16.302, 16.303, 16.305, 16.307, 16.309, 16.310, 16.313 និង 16.314 (ទាំងអស់នេះលើកឡើងអំពីអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវប្រឆាំងនឹងពួកវៀតណាម នៅស-២១)។ ទឡ្ហីករណ៍ 4.34, 18.239 និង 18.87 (ទាំងអស់នេះលើកឡើងអំពី ខៀវ សំផន បានដឹងពីច្បាប់លក្ខន្តិកៈស្តីពី បុគ្គលដែលត្រូវបានការការពាររបស់អ្នកជាប់ឃុំឃាំងនៅស-២១)។ ទឡ្ហីករណ៍ 18.348, 18.213 និង 18.70 (ទាំងអស់នេះលើកឡើងអំពី ខៀវ សំផន បានដឹងពីការចាប់ខ្លួន ការឃុំឃាំងខ្លួន ការធ្វើបាប និងការសម្លាប់)។ ទឡ្ហីករណ៍ 18.40, 18.41, 18.64 និង 18.207 (ទាំងអស់នេះលើកឡើងអំពី ខៀវ សំផន បានដឹងពី ឧក្រិដ្ឋកម្មប្រឆាំងនឹងអតីតពួកមេដឹកនាំខ្មែរក្រហម)។ ទឡ្ហីករណ៍ 18.205 និង 18.34 (ទាំងពីរនេះលើកឡើងអំពី ខៀវ សំផន បានរួមចំណែកនៅក្នុងការបោសសម្អាត) និង ទឡ្ហីករណ៍ 12.27, 12.28 និង 5.37 (ទាំងអស់នេះលើកឡើងអំពី ទំនាក់ទំនងរវាង បកក និង ស-២១)។

11. ការអនុញ្ញាតលើសំណើរបស់ ខៀវ សំផន គឺដូចគ្នាទៅនឹងការលើកទឹកចិត្តភាគីនានាឲ្យដាក់សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខ ដែលមានទឡ្ហីករណ៍ជាច្រើនតាមដែលអាចធ្វើទៅបាន ទោះបីជាត្រូវបានលើកឡើងក្នុងលក្ខណៈអន់យ៉ាងណា ឬគ្មានខ្លឹមសារយ៉ាងណាក៏ដោយ ដើម្បីផ្ដល់លទ្ធភាពឲ្យភាគីធ្វើយុត្តិកម្មសំណើសុំក្រោយៗមកទៀតក្នុងការបន្ថែមពេល និងចំនួនទំព័រដ៏ច្រើន ដើម្បីធ្វើពង្រាងសារណាបណ្ដឹងសាទុក្ខ។

### *(iii) ខៀវ សំផន មិនយកចិត្តទុកដាក់ទៅនឹងការពិចារណានានាដែលពាក់ព័ន្ធ*

12. ខៀវ សំផន បានលើកឡើងដោយខុសឆ្គងថា អង្គជំនុំជម្រះតុលាការកំពូលបានបង្ហាញពីការចង់បានល្បឿននៃកិច្ចដំណើរការនីតិវិធី ជាងសិទ្ធិរបស់មេធាវីការពារក្ដី22។ មូលដ្ឋានតែមួយគត់ដែលបានលើកឡើង ហើយដែលតាមពិតទៅត្រូវបានគូសបញ្ជាក់នោះ[23] គឺសេចក្ដីសម្រេចលើសំណើសុំពន្យារពេល និងចំនួនទំព័រ សម្រាប់សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខរបស់ភាគីទាំងឡាយ។ នៅក្នុងនោះ អង្គជំនុំជម្រះតុលាការកំពូលគ្រាន់តែបានកត់សំគាល់ថា វាត្រូវបាន "**ពិចារណាទៅលើ**ភាពចាំបាច់ក្នុងការធានាឲ្យបាននូវកិច្ចដំណើរការនីតិវិធីឆាប់រហ័ស ដោយស្របតាមក្របខ័ណ្ឌការងារផ្នែកច្បាប់របស់ អ.វ.ត.ក និងបទដ្ឋានអន្តរជាតិ"[24]។

13. ជាលទ្ធផល សំណើរបស់ ខៀវ សំផន មើលរំលងសិទ្ធិ និងផលប្រយោជន៍របស់ជនរងគ្រោះ និងដើមបណ្ដឹងរដ្ឋប្បវេណី ជាពិសេស ដោយយោងទៅលើវ័យកាន់តែចាស់ និងកង្វល់ផ្នែកសុខភាពរបស់ពួកគាត់ មិនត្រូវឲ្យនីតិវិធីតុលាការពន្យារពេលទៅដោយហួសហេតុនោះទេ[25]។ ដូចដែល

---

[22] ឯកសារ **F45** សំណើរបស់ ខៀវ សំផន កថាខណ្ឌ ២៣។

[23] ឯកសារ **F45** សំណើរបស់ ខៀវ សំផន កំណត់សម្គាល់ជើងទំព័រលេខ ២៧។

[24] ឯកសារ **F44/1** សេចក្ដីសម្រេចលើសំណើរបស់ ខៀវ សំផន សុំឲ្យពិចារណាឡើងវិញនូវសេចក្ដីសម្រេចអំពីការស្នើសុំបន្ថែមពេលវេលា និងចំនួនទំព័រ លើសេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខ ទំព័រទី ៣។

[25] *សូមអាន ឧទា. រដ្ឋអាជ្ញា ទល់នឹង Thomas Lubanga* សំណុំរឿង ICC-01/04/-01/06 សេចក្ដីសម្រេចស្ដីពីការរៀបចំទំហំនៃការផ្ដល់សំណងដែល Thomas Lubanga Dyilo ត្រូវទទួលខុសត្រូវ ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៧ កថាខណ្ឌ ២៣៤ "ទោះបីជាការកំណត់អត្តសញ្ញាណកម្មបុគ្គល មានចំនួនចំនួនច្រើនជាងជនរងគ្រោះដែលត្រូវរៀបចំទំហំស្ដីពីការផ្ដល់សំណងនឹងត្រូវបានគេចង់បានក៏ដោយ ក៏ការប្រឹក្សាយោបល់ចាំបាច់ត្រូវអូសបន្លាយនីតិវិធីឥតសមហេតុផល ដែលការបាត់បង់សិទ្ធិនេះមិនត្រឹមតែចំពោះលោក Lubanga ក្នុងការបានជូនដំណឹងនៅក្នុងរយៈពេលមួយដ៏សមហេតុសមផលប៉ុណ្ណោះទេ [...] ក៏ប៉ុន្តែថែមទាំងសិទ្ធិរបស់ពួកជនរងគ្រោះក្នុងការបានទទួលនូវសំណងដ៏ឆាប់រហ័សថែមទៀតផង ដែលនៅក្នុងការផ្សារភ្ជាប់គ្នានេះ អង្គជំនុំជម្រះរំលឹកឡើងវិញថា ខ្លួនត្រូវតែព្យាយាមឲ្យមានតុល្យភាពត្រឹមត្រូវរវាងសិទ្ធិ និងផលប្រយោជន៍របស់ជនរងគ្រោះ ហើយនិងសិទ្ធិ និងផលប្រយោជន៍ របស់ជនដែលត្រូវបានផ្ដន្ទាទោស"។ វិធាន ១០១(១) នៃវិធានស្ដីពីនីតិវិធី និងភ័ស្តុតាងរបស់ ICC "នៅក្នុងការធ្វើដីកាសម្រេចណាមួយ ដែលចែងពីពេលវេលាកំណត់ពាក់ព័ន្ធនឹងដំណើរការនៃកិច្ចដំណើរការនីតិវិធីណាមួយ តុលាការត្រូវ

ខៀវ សំផន អាចប្រមើលដឹងតម្រូវការចាំបាច់ឲ្យមានកិច្ចដំណើរការនីតិវិធីមួយដ៏ឆាប់រហ័ស មិនមែនជាវិធីមួយនៃការកាត់បន្ថយសិទ្ធិរបស់មេធាវីការពារក្តីនោះទេ[26] វាគឺជាការពិចារណាដែលសមស្របសម្រាប់អង្គជំនុំជម្រះតុលាការកំពូល ដែលត្រូវបានកំណត់ដោយវិធានផ្ទៃក្នុង និងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក[27]។

14. តាមពិត អង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង០០២/១ បានចង្អុលបង្ហាញថា ការដកចេញការប្រកាសអំពីការផ្តន្ទាទោស និងការសម្រេចអំពីទោសលើបណ្តឹងសាទុក្ខ និងការហាមឃាត់លើការបញ្ជូនត្រឡប់រឿងក្តីមួយទៅជំនុំជម្រះឡើងវិញ "បង្ហាញនូវការផ្តោតលើលើការពន្លឿនកិច្ចដំណើរការនីតិវិធី"[28]។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ដំណើការបណ្តឹងសាទុក្ខ*ដ៏មានកម្រិត* នេះនៅ អ.វ.ត.ក តាមពិតត្រូវបានប្រើ "ដើម្បីការពារផលប្រយោជន៍ជនជាប់ចោទ"[29]។

## *(iv) សំណើរបស់ ខៀវ សំផន មានភាពហួសហេតុ និងមិនសមហេតុផល បើប្រៀបធៀបទៅនឹងការបន្ថែមដែលបានអនុញ្ញាតសម្រាប់រឿងក្តីទំហំស្រដៀងគ្នា នៅកម្រិតអន្តរជាតិ*

15. អង្គជំនុំជម្រះតុលាការកំពូលបានកត់សំគាល់ថា សាលក្រមលើសំណុំរឿង០០២/០២ "គឺប្រហាក់ប្រហែលនឹងសាលក្រមនានានៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌមួយចំនួនដែលស្មុគស្មាញជាងគេដែលត្រូវបានជំនុំជម្រះនៅចំពោះមុខតុលាការអន្តរជាតិផ្សេងទៀតៗ"[30] តាមពិតនោះ សាលក្រមខ្លះក្នុងចំណោមសាលក្រមទាំងឡាយបានយោងសំអាងដោយអង្គជំនុំជម្រះតុលាការកំពូល គឺ

---

ពិនិត្យមើលភាពចាំបាច់ដើម្បីសម្របសម្រួលដល់កិច្ចដំណើរការនីតិវិធីឲ្យបានត្រឹមត្រូវ និងឆាប់រហ័ស ដោយខ្សែកដោយកំណត់ក្នុងចិត្តអំពីសិទ្ធិរបស់មេធាវីការពារក្តី និងសិទ្ធិជនរងគ្រោះ"។

[26] ឯកសារ **F45** សំណើរបស់ ខៀវ សំផន កថាខណ្ឌ២៥។

[27] *សូមមើល* អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង (វ.១៦ មករា ឆ្នាំ២០១៥) វិធាន ២១(៤) នៃផ្ទៃក្នុង "ការសម្រេចសេចក្តីលើការចោទប្រកាន់ចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ ត្រូវធ្វើការជំនុំជម្រះក្នុងរយៈពេលមួយសមស្រប។" ("វិធានផ្ទៃក្នុង") សូមមើលផងដែរ វិធាន ៧៩(៧) "ដើម្បីសម្របសម្រួលដល់ការប្រព្រឹត្តិទៅនៃកិច្ចដំណើរការនីតិវិធីប្រកបដោយយុត្តិធម៌ និងឆាប់រហ័ស អង្គជំនុំជម្រះសាលាដំបូង អាចពិគ្រោះយោបល់ជាមួយភាគីទាំងឡាយ ដោយធ្វើការប្រជុំរៀបចំសវនាការ [...]"។ ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សម្រាប់កាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ ន.ស/រ.ក.ម/១០០៤/០៦ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ មាត្រា ៣៣*ថ្មី* ។ "អង្គជំនុំជម្រះវិសាមញ្ញរបស់សាលាដំបូងត្រូវប្រព្រឹត្តទៅឱ្យបានត្រឹមត្រូវ និងឆាប់រហ័សទៅតាមនីតិវិធីជាធរមាន ដោយមានការគោរពយ៉ាងពេញលេញនូវសិទ្ធិរបស់ជនត្រូវចោទ និងមាន ការការពាឱ្យបានត្រឹមត្រូវចំពោះ ជនរងគ្រោះ និង សាក្សី"។

[28] ឯកសារ **F36** សាលដីកាសំណុំរឿង០០២/០១, កថាខណ្ឌ ៩៤។

[29] *ដូចជើងទំព័រខាងលើ*។

[30] ឯកសារ **F43** កថាខណ្ឌ ៨។

*វែងជាង* សាលក្រម ក្នុងសំណុំរឿង០០២/០២ ទៅទៀត ដូចជា សាលក្រមដែលបានចេញប្រឆាំងទៅនឹង Radovan Karadžić (២៥៩០ទំព័រ), Charles Taylor (២៥៣២ទំព័រ), និង Ratko Mladić (២៤៧៨ទំព័រ)។ គួរកត់សំគាល់ថា ទាំងនេះក៏សុទ្ធតែជាសវនាការលើជនជាប់ចោទតែម្នាក់ផងដែរ មានន័យថា គ្រប់ទំព័រទាំងអស់នៃសាលក្រមនេះ ជាប់ទាក់ទងផ្ទាល់ទៅនឹងជនដែលត្រូវបានផ្តន្ទាទោស នៅដំណាក់កាលបណ្តឹងសាទុក្ខ មិនដូចជាស្ថានភាពបច្ចុប្បន្ននេះទេ។

16. ដូចមានបង្ហាញនៅក្នុងតារាងខាងក្រោម ការប្រៀបធៀបការបន្ថែមចំនួនពេលវេលា និងទំព័រកំណត់ ដែលបានអនុញ្ញាតនៅក្នុងសំណុំរឿងទាំងនេះ ទៅនឹងសំណើរបស់ ខៀវ សំផន ស្នើសុំរយៈពេល ១០ខែកន្លះ (ប្រមាណជា ៣១៥ថ្ងៃ) និង ៩៥០ទំព័រ ដើម្បីដាក់សារណាបណ្តឹងសាទុក្ខរបស់គាត់នេះ បង្ហាញឱ្យឃើញថា ចំនួនបន្ថែមដែលបានស្នើសុំនេះ មានទំហំលើសពីនិយាម នៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ។ សំណើរបស់ ខៀវ សំផន គឺមានចំនួន ២,៥ដង ទៅ ៤,៥ដង នៃចំនួនពេលវេលាដែលផ្តល់ជូន និងប្រមាណជា ៥ដង នៃចំនួនទំព័រ ដែលបានផ្តល់ឱ្យនៅក្នុងការជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌអន្តរជាតិដែលមានទំហំប្រហាក់ប្រហែលគ្នានេះ។

| | | Mladić | Karadžić | Taylor |
|---|---|---|---|---|
| **សារណាបណ្តឹងសាទុក្ខ** | វិធានជាធរមានស្តីពីពេលវេលា | ៧៥ថ្ងៃ (ចាប់ពីសេចក្តីជូនដំណឹងពីបណ្តឹងសាទុក្ខ)[31] | | ២១ថ្ងៃ (ចាប់ពីសេចក្តីជូនដំណឹងពីបណ្តឹងសាទុក្ខ)[32] |

[31] យន្តការសេសសល់អន្តរជាតិសម្រាប់តុលាការព្រហ្មទណ្ឌ វិធានស្តីពីនីតិវិធី និងភស្តុតាង (វិ. ៤ មីនា ២០១៩) វិធាន ១៣៨។

[32] តុលាការពិសេសសម្រាប់សៀរ៉ាលេអូន វិធានស្តីពីនីតិវិធី និងភស្តុតាង (វិ. ៣១ ឧសភា ២០១២) វិធាន ១១១។

| | | | | |
|---|---|---|---|---|
| | ពេលដែលផ្តល់ឲ្យ | ១៣៥ថ្ងៃ[33] | ១៣៥ថ្ងៃ[34] | ៧៤ថ្ងៃ[35] |
| | វិធានជាធរមានស្តីពីកម្រាស់ | ៣០០០០ពាក្យ[36] | | ១០០ទំព័រ ឬ ៣០០០០ពាក្យ[37] |
| | ពាក្យ/ទំព័រដែលផ្តល់ឲ្យ | ៧៥០០០ពាក្យ (ប្រហែល២៥០ ទំព័រ)[38] | ៧៥០០០ពាក្យ (ប្រហែល២៥០ ទំព័រ)[39] | ៤០០ទំព័រ ឬ ១២០០០០ពាក្យ – **<u>សារុបទាំងពីរ៖</u>** បណ្តឹងសាទុក្ខ និង សារណាចម្លើយតប[40] |

### *(v) សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាលើកាលបរិច្ឆេទកំណត់ និងការបន្ថែមចំនួនទំព័រសម្រាប់សារណាបណ្តឹងសាទុក្ខរបស់ភាគី*

17. សហព្រះរាជអាជ្ញាយល់ឃើញថា រយៈពេល៥ខែ និង៣០០ទំព័រ សម្រាប់ក្រុមមេធាវីការពារក្តីនីមួយៗ ដើម្បីដាក់សារណាបណ្តឹងសាទុក្ខ ក្នុងមួយភាសា គឺមានភាពសមស្រប។

[33] *រដ្ឋអាជ្ញា ទល់នឹង Mladić,* MICT-13-56-A, សេចក្តីសម្រេចលើញត្តិរបស់ Ratko Mladić សុំបន្ថែមពេលវេលា និងចំនួនពាក្យកំណត់ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៨ ("សេចក្តីសម្រេចលើញត្តិសុំបន្ថែមរបស់ Mladić") ទំព័រ៤។

[34] *រដ្ឋអាជ្ញា ទល់នឹង Karadžić,* MICT-13-55-A, សេចក្តីសម្រេចលើញត្តិរួមសុំពន្យារពេលវេលាដាក់សារណាបណ្តឹងឧទ្ធរណ៍ និងសារណាចម្លើយតប ចុះថ្ងៃទី៩ ខែសីហា ឆ្នាំ២០១៦, ទំព័រ ៣។

[35] *រដ្ឋអាជ្ញា ទល់នឹង Taylor,* SCSL-03-01-A, សេចក្តីសម្រេចលើញត្តិរបស់អយ្យការ និងមេធាវីការពារក្តី សុំពន្យារពេលវេលា និងបន្ថែមជំនួនទំព័រកំណត់ សម្រាប់សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរអនុលោមតាមវិធាន ១១១, ១១២ និង ១១៣ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១២ ("សេចក្តីសម្រេចលើសំណើបន្ថែមក្នុងរឿងក្តី Taylor") ទំព័រ ១៣។ *រដ្ឋអាជ្ញា ទល់នឹង Taylor,* SCSL-03-01-A, សេចក្តីសម្រេចលើញត្តិរបស់មេធាវីការពារក្តីសុំឲ្យពិចារណាឡើងវិញ ឬពិនិត្យឡើងវិញនូវ "សេចក្តីសម្រេចលើញត្តិរបស់អយ្យការ និងមេធាវីការពារក្តី សុំពន្យារពេលវេលា និងបន្ថែមជំនួនទំព័រកំណត់ សម្រាប់សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរអនុលោមតាមវិធាន ១១១, ១១២ និង ១១៣" និងដីកាបង្គាប់ចុងក្រោយលើការព្យារពេលវេលា សម្រាប់ដាក់សេចក្តីសន្និដ្ឋាន ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១២ ទំព័រ៣។

[36] យន្តការសេសសល់អន្តរជាតិសម្រាប់តុលាការព្រហ្មទណ្ឌ សេចក្តីណែនាំអនុវត្តស្តីពីកម្រាស់សាណារ និងញត្តិ (វ. ៦ សីហា ២០១៣) កថាខណ្ឌ ៦។

[37] តុលាការពិសេសសម្រាប់សៀរ៉ាលេអូន សេចក្តីណែនាំអនុវត្តស្តីពីឯកសារនៅការិយាល័យរងរបស់ The Hague (វ. ២៥ មេសា ២០០៨) មាត្រា ៦ (ង)(ឈ)។

[38] សេចក្តីសម្រេចលើញត្តិសុំបន្ថែមរបស់ Mladić ទំព័រ៤។

[39] *រដ្ឋអាជ្ញា ទល់នឹង Karadžić,* MICT-13-55-A, សេចក្តីសម្រេចលើញត្តិសុំបន្ថែមចំនួនពាក្យកំណត់ ចុះថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០១៦ ទំព័រ៣។

[40] សេចក្តីសម្រេចលើសំណើបន្ថែមក្នុងរឿងក្តីTaylor ទំព័រ១៣។

ការណ៍នេះផ្អែកលើការពិចារណាអំពី៖ (i) ទំហំសំណុំរឿង០០២/០២ ធំជាងបើធៀបទៅនឹងសំណុំរឿង០០២/០១ ទាក់ទងនឹងប្រភេទ វិសាលភាព និងចំនួនឧក្រិដ្ឋកម្មដែលត្រូវវិនិច្ឆ័យ; (ii) រយៈពេល ៣ខែ និង ២១០ ទំព័រ ត្រូវបានអនុញ្ញាតសម្រាប់ការដាក់សារណាបណ្ដឹងសាទុក្ខរបស់មេធាវីការពារក្ដី ក្នុងសំណុំរឿង០០២/០១ ដោយផ្ដល់ឱ្យការបន្ថែមពេល ៣០ថ្ងៃ និងប្រមាណ ១៨០ ទំព័រ (iii) ការអនុវត្តរបស់តុលាការអន្តរជាតិផ្សេងទៀត ក្នុងរឿងក្ដីទំហំស្រដៀងគ្នានេះ (iv) សិទ្ធិទទួលបានពេលវេលាគ្រប់គ្រាន់ ដើម្បីរៀបចំសារណា (v) ភាពចាំបាច់សម្រាប់កិច្ចដំណើរការនីតិវិធីឆាប់រហ័យ និង (vi) ផលប្រយោជន៍របស់ជនរងគ្រោះក្នុងការឃើញយុត្តិធម៌ត្រូវបានបញ្ចប់ក្នុងរយៈពេលសមស្រប។

18. សហព្រះរាជអាជ្ញាមិនជំទាស់នឹងការពន្យារពេល និងការបន្ថែមចំនួនទំព័រសមស្របសម្រាប់ចម្លើយតបរបស់មេធាវីការពារក្ដីទៅនឹងសារណាបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាឡើយ ដោយកត់សម្គាល់ថា សហព្រះរាជអាជ្ញានឹងដាក់សារណាបណ្ដឹងសាទុក្ខរបស់ខ្លួនក្នុងពេលវេលា និងចំនួនទំព័រកំណត់ដែលមានចែងក្នុងវិធានផ្ទៃក្នុង។ សហព្រះរាជអាជ្ញាស្នើសុំថា ការបន្ថែមណាមួយដែលត្រូវបានផ្ដល់ឱ្យទៅមេធាវីការពាក្ដី សម្រាប់ការដាក់បណ្ដឹងសាទុក្ខរបស់ពួកគេ នឹងត្រូវបន្ថែមឱ្យសហព្រះរាជអាជ្ញាក្នុងលក្ខណៈសមាមាត្រគ្នា សម្រាប់ការដាក់សារណាចម្លើយតបរបស់ខ្លួន ដើម្បីធានាសមភាពរវាងភាគី ឱ្យបានច្រើនដូចដែលអាចធ្វើបាន។

### *(vi) ភាគីគួររៀបចំសារណាបណ្ដឹងសាទុក្ខរបស់ខ្លួនស្របតាមវិធានផ្ទៃក្នុង និងយុត្តិសាស្ត្ររបស់ អ.វ.ត.ក*

19. សហព្រះរាជអាជ្ញាកត់សម្គាល់ឃើញភាពមិនច្បាស់លាស់ នៅក្នុងសេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន និងរំលឹកអំពីការសន្និដ្ឋានរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង០០២/០១ ថា មេធាវីការពារក្ដី ខៀវ សំផន ត្រូវ "លុបផ្នែកដែលជាប់ទាក់ទង នៅក្នុងកថាខណ្ឌដែលគេមើលឃើញយ៉ាងជាក់ស្ដែងនៅក្នុងសារណាបណ្ដឹងសាទុក្ខរបស់ខ្លួន ទៅនឹងទទ្បីរណ៍ដែលឆ្លើយឆ្លងគ្នានៃបណ្ដឹងសាទុក្ខ នៅក្នុងសេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខរបស់គាត់ ហើយអំណះអំណាងខ្លះទៀតនៃអំណះអំណាងទាំងនេះ ហាក់ដូចជាត្រូវបានគ្របដណ្ដប់ដោយទទ្បីរណ៍មួយចំនួននៃបណ្ដឹងសាទុក្ខ"[41]។

20. ជាលទ្ធផល សហព្រះរាជអាជ្ញាស្នើសុំឱ្យណែនាំភាគីទាំងឡាយឱ្យ (i) បញ្ជាក់អំពីទទ្បីករណ៍ ឬទទ្បីករណ៍រង ឱ្យបានច្បាស់លាស់សម្រាប់សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខរបស់ខ្លួន ដែលកំពុង

[41] **F18/3** សេចក្ដីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងសារណាបណ្ដឹងឧទ្ធរណ៍របស់ ខៀវ សំផន ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ ទំព័រ៥។

ត្រូវបានតវ៉ាក្នុងទឡ្ហីករណ៍ជាក់លាក់ណាមួយនៃបណ្តឹងសាទុក្ខ នៅក្នុងសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ។ (ii) ផ្តល់អំណះអំណាងទឡ្ហីករណ៍ ឬទឡ្ហីករណ៍រងនីមួយៗតែម្តងគត់នៅក្នុងសារណាបណ្តឹងសាទុក្ខ និង (iii) កំណត់អត្តសញ្ញាណទឡ្ហីករណ៍ ឬទឡ្ហីករណ៍រងណាមួយពីសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខដែលមិនបានបញ្ចូលនៅក្នុងសារណាបណ្តឹងសាទុក្ខ[42] និង (iv) "បង្ហាញពី *ការប៉ះពាល់* ជានិរន្តរ៍" និងទំនាក់ទំនងរវាងសេចក្តីសម្រេចបន្ទាន់បង្គំណាមួយ ដែលត្រូវបានប្តឹងសាទុក្ខ និងទឡ្ហីករណ៍មួយ ឬ ពីរ ដែលអាចមានក្នុងបណ្តឹងសាទុក្ខលើសាលក្រមអង្គជំនុំជម្រះ[43]។

### *(vii) សំណើជាជម្រើសផ្សេងរបស់ ខៀវ សំផន សុំឱ្យមានសវនាការជាសាធារណៈ*

21. សហព្រះរាជអាជ្ញាមិនជំទាស់នឹងសវនាការជាសាធារណៈទេ ប្រសិនបើសវនាការនោះចាំបាច់។ ទោះជាយ៉ាងណា ខៀវ សំផន ខកខានមិនបានផ្តល់យុត្តិកម្មសំណើរបស់គាត់ស្នើសុំសវនាការជាសាធារណៈក្នុងកាលៈទេសៈទាំងនេះទេ។[44] មូលហេតុរបស់ ខៀវ សំផន សម្រាប់សំណើនេះគឺដើម្បីធ្វើឱ្យកិច្ចដំណើរការនីតិវិធីមាន "លក្ខណៈជាមនុស្ស" និងអនុញ្ញាតឱ្យគាត់ធានាបានថា "ឧបសគ្គជាក់ស្តែង" ដែលគាត់សំដៅលើត្រូវបានបង្ហាញទៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល[45]។ ទោះជាយ៉ាងណា ខៀវ សំផន បានលើកឡើងជាដដែលៗនូវបញ្ហាដូចគ្នានេះ[46] អង្គជំនុំជម្រះតុលាការកំពូលដឹងច្បាស់អំពីកង្វល់របស់គាត់រួចហើយ និងអាចទាក់ទងទៅកាន់ការិយាល័យរដ្ឋបាល និងអង្គភាពបកប្រែភាសាផ្ទៃក្នុងសម្រាប់ព័ត៌មានបន្ថែម ប្រសិនបើត្រូវការ។

## IV. ដំណោះស្រាយដែលស្នើឡើង

22. ផ្អែកលើមូលហេតុដូចបានរៀបរាប់ខាងលើ សហព្រះរាជអាជ្ញាសុំស្នើទៅអង្គជំនុំជម្រះតុលាការកំពូលឱ្យ៖ (i) បដិសេធសំណើរបស់ ខៀវ សំផន សុំរយៈពេល១០ខែកន្លះ និង៩៥០ទំព័រ សម្រាប់

---

[42] *សូមមើល* វិធាន ១០៥(៣) នៃវិធានផ្ទៃក្នុង។

[43] ឯកសារ F9 សេចក្តីសម្រេចលើសំណើសុំពន្យារយៈពេល និងបន្ថែមចំនួនទំព័រសម្រាប់សារណាបណ្តឹងសាទុក្ខ និងសារណាតប ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៤ កថាខណ្ឌ ១៦។

[44] ឯកសារ F45 សំណើរបស់ ខៀវ សំផន កថាខណ្ឌ ៤០។

[45] ឯកសារ F45 សំណើរបស់ ខៀវ សំផន កថាខណ្ឌ ៤០។

[46] *សូមមើល* ឯកសារ F39/1.1 សំណើសុំទាក់ទងនឹងសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ២៨-៣៤។ ឯកសារ F41/1 ការឆ្លើយតប និងចម្លើយតបរបស់លោក ខៀវ សំផន ទៅនឹងសហព្រះរាជអាជ្ញាស្តីពីការបន្ថែមពេលវេលា និងបង្កើនចំនួនទំព័រ នៃសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៩ កថាខណ្ឌ១៨-២៤។ ឯកសារ F42/1 ការឆ្លើយតបរបស់លោក ខៀវ សំផន ទៅនឹងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ស្តីពីការបន្ថែមពេលវេលា និងបង្កើនចំនួនទំព័រនៃសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៩ កថាខណ្ឌ៩-១១។

សារណាបណ្ដឹងសាទុក្ខរបស់គាត់ និងផ្ដល់ការបន្ថែមដ៏សមស្រប; (ii) ផ្ដល់ឲ្យសហព្រះរាជអាជ្ញា សម្រាប់សារណាចម្លើយតបរបស់ខ្លួននូវការបន្ថែម សមមាត្រទៅនឹងការផ្ដល់ឲ្យទៅមេធាវីការពារក្ដី សម្រាប់សារណាបណ្ដឹងសាទុក្ខរបស់ពួកគាត់ដែរ និង (iii) ណែនាំភាគីទាំងឡាយឲ្យរៀបចំសារណារបស់ពួកគេក្នុងរបៀបមួយដែលផ្ទុះបញ្ចាំង និង ចង្អុលបង្ហាញ យ៉ាងច្បាស់លាស់អំពីសេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខរបស់ខ្លួន ដោយជៀសវាងការលើកឡើងដដែលៗមិនចាំបាច់ និងអនុវត្តតាមវិធានផ្ទៃក្នុង និងយុត្តិសាស្ត្រ អ.វ.ត.ក៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៩ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | **លោក** William SMITH<br>សហព្រះរាជអាជ្ញាអន្តរជាតិរង ជួស<br>**លោកស្រី** Brenda J. HOLLIS<br>សហព្រះរាជអាជ្ញាអន្តរជាតិបម្រុង | | [signature] |